ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៤៩ ក.យ.ប្រក/២៤

# ប្រកាស
# ស្តីពី
# ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៥៨ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការផ្ទេររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

## សម្រេច

**ប្រការ១ .-**

ត្រូវបានកំណត់ឱ្យជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ចំនួន ១៥ (ដប់ប្រាំ) រូប តាមរយៈការប្រឡងប្រជែង ពីក្នុងចំណោមមន្ត្រីរាជការក្នុងវិស័យយុត្តិធម៌ និងក្រឡាបញ្ជី។



KR

មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

**ប្រការ២** .-

ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ មាន ២ (ពីរ) ដំណាក់កាល៖

**១-ដំណាក់កាលទី១៖** ការប្រឡងប្រជែងលើវិញ្ញាសាសរសេរ **មានចំនួន ២ (ពីរ) មុខវិជ្ជា** គឺ៖

-**នីតិព្រហ្មទណ្ឌ** (នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស) **និងនីតិវិធីព្រហ្មទណ្ឌ** រយៈពេល ៣ (បី) ម៉ោង មេគុណ ១ (មួយ)

-**នីតិរដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី** រយៈពេល ៣ (បី) ម៉ោង មេគុណ ១ (មួយ)

ករណីបេក្ខជនដែលអវត្តមានក្នុងការប្រឡងប្រជែង ចំពោះវិញ្ញាសាណាមួយក្នុងចំណោមមុខវិជ្ជាទាំងពីរខាងលើនឹងត្រូវធ្លាក់ដោយស្វ័យប្រវត្តិ។

ការប្រឡងប្រជែងលើវិញ្ញាសាសរសេរខាងលើនឹងប្រព្រឹត្តទៅនៅ**ថ្ងៃសុក្រ ទី១ ខែមេសា ឆ្នាំ២០២២**។

**២-ដំណាក់កាលទី២៖** ការប្រឡងប្រជែងលើវិញ្ញាសាសួរផ្ទាល់មាត់លើ **មុខវិជ្ជាវប្បធម៌ទូទៅ** ពាក់ព័ន្ធនឹងវិស័យច្បាប់ និងយុត្តិធម៌។

រយៈពេលសម្រាប់ការត្រៀម សួរ និងឆ្លើយសំណួរត្រូវកំណត់ដោយក្រសួងយុត្តិធម៌។

ចំពោះកាលបរិច្ឆេទនៃការប្រឡងប្រជែងវិញ្ញាសាសួរផ្ទាល់មាត់ ក្រសួងយុត្តិធម៌ នឹងជូនដំណឹងនៅពេលក្រោយ។

**ប្រការ៣** .-

លក្ខខណ្ឌនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ត្រូវបានកំណត់ចំពោះបេក្ខជនជាមន្ត្រីរាជការក្នុងវិស័យយុត្តិធម៌ និងក្រឡាបញ្ជី ដូចខាងក្រោម៖

១- ត្រូវមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រច្បាប់ឡើងទៅ

២- ត្រូវមានបទពិសោធន៍ក្នុងវិស័យច្បាប់ ឬយុត្តិធម៌ យ៉ាងតិច ៥ (ប្រាំ) ឆ្នាំ

៣- មានអាយុមិនលើសពី ៤៥ (សែសិបប្រាំ) ឆ្នាំ គិតមកដល់ថ្ងៃប្រឡង

៤- មិនដែលមានទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋ

៥- ត្រូវមានកាយសម្បទាគ្រប់គ្រាន់អាចបំពេញការងារបាន។

**ប្រការ៤** .-

ការរៀបចំ បែបបទ និងនីតិវិធីនៃការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

បេក្ខជនដែលបានប្រឡងជាប់ស្ថាពរសម្រាប់ការប្រឡងប្រជែងជ្រើសរើសសិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ត្រូវទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រមនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដោយត្រូវអនុញ្ញាតឱ្យចូលរៀននៅក្នុងចំណោមសិស្សចៅក្រមជំនាន់ទី១១ នៅសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ ត្រូវអនុវត្តដូចគ្នានឹងការរៀបចំ និងការប្រព្រឹត្តទៅនៃការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ជំនាន់ទី១១ លើកលែងតែមុខវិជ្ជាមួយចំនួន ដែលអាចត្រូវបានលើកលែងដោយសេចក្តីសម្រេចដោយឡែករបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។



KR

**ប្រការ៥ .-**

សមាសភាពគណៈមេប្រយោគ និងគណៈកម្មការនានា ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចចាត់វិធានការនានា ដើម្បីធានាប្រសិទ្ធភាព តម្លាភាព និងដំណើរការល្អនៃការប្រឡងប្រជែង។

**ប្រការ៦ .-**

ឧទ្ទកាល័យរដ្ឋមន្ត្រី រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋានកិច្ចការតុលាការ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ KR

ថ្ងៃពុធ ៧កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

<u>កន្លែងទទួល៖</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ